# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៩ ខែមិនា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៩៩,៣៨២ ដុល្លារអាមេរិក សម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពជីវភាពក្នុងខេត្តកំពង់ធំ



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុនជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ)រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ៩៩,៣៨២ដុល្លាអាមេរិកដល់មន្ទីរធនធានទឹកនិងឧតុនិយមខេត្តកំពង់ធំសម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពជីវភាពខេត្តកំពង់ធំ។កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយលោក តាស៊ីយ៉ា ម៉ាជីដា ទីប្រឹក្សាស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម ជាតិ ស៊ីវុត្ថា ប្រធានមន្ទីរ ធនធានទឹក និងឧតុនិយមខេត្តកំពង់ធំនៅស្ថានទូតជប៉ុន។



ជាមួយនឹងជំនួយនេះប្រព័ន្ធស្រោចស្រពជីវភាពនឹងត្រូវបានជួសជុលដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្តកំពង់ធំ។ គម្រោងនេះរួមបញ្ចូលការជួសជុលទំនប់អាងទឹកប្រវែង៤០០ម៉ែត្រការជួសជុលប្រឡាយមេប្រវែង ២,២០០ម៉ែត្រ និងការសាងសង់សំណង់ស្នាក់ទឹក២កន្លែង។ យើងរំពឹងថា វានឹងកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ដែលកើតមានឡើងជារៀងរាល់ឆ្នាំនិងសម្រួលដល់ការងារស្រោចស្រពរបស់ប្រជាកសិករប្រមាណ ១,១៥០គ្រួសារនៅក្នុងតំបន់។ដោយមានជំនួយផ្នែកបច្ចេកទេសពីមន្ទីរធនធានទឹកនិងឧតុនិយមខេត្តកំពង់ធំប្រជាសហគមន៍នឹងថែទាំប្រព័ន្ធស្រោចស្រពនេះឲ្យមានសភាពល្អជានិច្ច។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបាន

ផ្តល់ថវិកាជាង៤៧.៥លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាននិងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៤៧៤គម្រោងនៅទូទាំងប្រទេស។



*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*